Co-funded by
the European Union

# សេចក្តីប្រកាសព័ត៌មាន

## កម្ពុជា៖ គម្រោងអភិវឌ្ឍន៍ជលផលក្រោយប្រមូលផល ( CAPFISH-Capture ) ទទួលបានពានរង្វាន់លើកកម្ពស់សមភាពយេនឌ័រឆ្នាំ ២០២៣

**ភ្នំពេញ ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២៣៖** ពានរង្វាន់លើកកម្ពស់សមភាពយេនឌ័រ (GEM Award) ឆ្នាំ២០២៣ ត្រូវបានប្រគល់ជូនក្រុមការងារគម្រោងអភិវឌ្ឍន៍ជលផលក្រោយប្រមូលផល (CAPFISH-Capture) នៅប្រទេសកម្ពុជា ក្នុងមហាសន្និបាតរបស់អង្គការសហប្រជាជាតិដើម្បីអភិវឌ្ឍន៍ឧស្សាហកម្ម (UNIDO) កាលពីថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២៣ នៅទីក្រុងវីយែន ប្រទេសអូទ្រីស។ ពានរង្វាន់នេះឆ្លុះបញ្ចាំងអំពីការទទួលស្គាល់កិច្ចខិតខំប្រឹងប្រែង និងការរួមចំណែករបស់គម្រោងក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីនៅក្នុងវិស័យជលផលនៅកម្ពុជា។ ប្រធានបទនៃពានរង្វាន់គឺ «ការធ្វើឱ្យសមភាពយេនឌ័រក្លាយជាការពិតនៅក្នុងឧស្សាហកម្ម»។

វិស័យជលផលនៅកម្ពុជាមានសារៈសំខាន់ណាស់សម្រាប់សេដ្ឋកិច្ច និងសន្តិសុខស្បៀង ដោយប្រជាជនប្រមាណ ៤០% ពឹងផ្អែកដោយផ្ទាល់សម្រាប់ការចិញ្ចឹមជីវិត និងផ្គត់ផ្គង់ជីវភាព។ ភាគច្រើនជាស្ត្រី ដែលដើរតួនាទីនាំមុខ និងជាម្ចាស់សហគ្រាសកែច្នៃផល ផលិតផលជលផលខ្នាតមីក្រូ តូច និងមធ្យម (MSMEs) ជាអ្នកទទួលបន្ទុកដោយផ្ទាល់ក្នុងការកែច្នៃ ការងារទីផ្សារ លក់រាយ និងចែកជាយផលិតផលជលផលទាំងនេះនៅទូទាំងប្រទេសតែម្តង។ ថ្វីបើស្ត្រីដើរតួនាទីយ៉ាងសំខាន់នៅក្នុងខ្សែច្រវ៉ាក់តម្លៃជលផលទាំងមូល រួមទាំងវារីវប្បកម្មក៏ដោយ ការចូលរួមរបស់ស្ត្រីជារឿយៗត្រូវបានចាត់ទុកថាជាកិច្ចការបន្ថែមលើការងារផ្ទះសម្បែងតែប៉ុណ្ណោះ និងមិនមានតម្លៃសេដ្ឋកិច្ច ហើយមិនត្រូវបានយកមកពិចារណានៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តនោះទេ។

វិសមភាពយេនឌ័រ ជាកត្តារាំងស្ទះសម្រាប់ស្ត្រីក្នុងការទទួលបានឱកាសអភិវឌ្ឍ និងពង្រឹងជំនាញ ដែលជាកត្តាជាសារវន្តដល់ការចូលរួមផ្នែកសេដ្ឋកិច្ច និងសង្គមរបស់ខ្លួន។ បន្ថែមពីលើកត្តាពេលវេលា និងទំនួលខុសត្រូវការងារផ្ទះ និងការមើលថែទាំសមាជិកគ្រួសារ ស្ត្រីក៏ប្រឈមមុខនឹងការរើសអើងផ្នែកយេនឌ័រ ដែលពុំអាចឱ្យពួកគាត់ស្វែងរកគោលដៅការងារខ្លួន ក៏ដូចជាភាពជោគជ័យក្នុងវិស័យជលផលផ្ទាល់តែម្តង។ ការបង្កើតឱកាសឱ្យស្ត្រីអាចអភិវឌ្ឍជំនាញ និងដោះស្រាយបញ្ហាប្រឈមដូចបានរៀបរាប់ខាងលើ នឹងផ្តល់ភាពអង់អាចដល់ស្ត្រីឲ្យទទួលបានតួនាទីជាអ្នកដឹកនាំ និងជំរុញបរិយាកាសប្រកបដោយសមធម៌ និងបរិយាប័ន្ននៅក្នុងខ្សែចង្វាក់តម្លៃទាំងមូល។

គម្រោង CAPFISH-Capture គាំទ្រថវិកាដោយសហភាពអឺរ៉ុប (EU) មានគោលដៅរួមចំណែកអភិវឌ្ឍវិស័យជលផលក្រោយប្រមូលផល តាមរយៈការធ្វើឱ្យប្រសើរឡើងនូវក្របខណ្ឌគតិយុត្ត និងសមត្ថភាពស្ថាប័ន និងជម្រុញវិស័យឯកជនឱ្យទទួលយក និងអនុវត្តនវានុវត្តន៍ និងការអនុវត្តល្អប្រសើរពាក់ព័ន្ធ។ ដោយពិនិត្យលើតួនាទីដ៏លេចធ្លោរបស់ស្ត្រីក្នុងវិស័យជលផលក្រោយប្រមូលផល និងវិសមភាពយេនឌ័រដែលជាកត្តារាំងស្ទះពុំអាចឱ្យស្ត្រីបំពេញការងារឱ្យអស់សក្តានុពលបាន គម្រោងបានដាក់បញ្ចូលនូវវិធីសាស្ត្រគ្រប់គ្រងដែលគិតគូរពីយេនឌ័រនៅក្នុងកិច្ចអន្តរាគមន៍របស់ខ្លួន តាមរយៈការលើកកម្ពស់សមភាពយេនឌ័រ និងពង្រឹងភាពអង់អាចដល់ស្ត្រីនៅក្នុងវដ្តគម្រោងទាំងមូល។

**លោក សុខ ណារិន តំណាងអង្គការ UNIDO ប្រចាំប្រទេសកម្ពុជា** បានសាទរចំពោះគម្រោង CAPFISH-Capture ដែលទទួលបានពានរង្វាន់ GEM Award ។ លោកបានទទួលស្គាល់ថា «អភិក្រមសមភាពយេនឌ័ររបស់គម្រោង ពិតជាបានបង្កើតនូវបរិយាកាសប្រកបដោយបរិយាប័ន្ន ដែលមនុស្សគ្រប់គ្នាអាចរីកចម្រើន ដោយ ទុកនរណាម្នាក់ចោលឡើយ»។ លោកលើកឡើងថាអង្គការ UNIDO ពិតជាមានមោទនភាពណាស់ចំពោះកិច្ចខិតខំប្រឹងប្រែងជាបន្តបន្ទាប់របស់គម្រោងក្នុងការលើកកម្ពស់តួនាទី និងភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ជាពិសេសសហគ្រាសជលផល MSMEs ដែលដឹកនាំដោយស្ត្រី ។


023 900 974
CAPFish-Cambodia@unido.org
https://fia.maff.gov.kh | www.unido.org
No. 186, Norodom Boulevard, Phnom Penh, Cambodia

តាមរយៈកម្មវិធីគាំទ្រសហគ្រាសជលផលខ្នាតតូច និងមធ្យម (VCIS) គម្រោងបានផ្តល់ទាំងជំនួយបច្ចេកទេស និងសម្ភារ បរិក្ខារចាំបាច់ដល់សហគ្រាសកែច្នៃជលផលចំនួន ២៨ ដែលក្នុងនោះ សហគ្រាសដែលដឹកនាំដោយស្ត្រី មានចំនួន ២០។ ភាគច្រើននៃសហគ្រាសដែលដឹកនាំដោយស្ត្រីទាំងនេះ ទទួលបានវិញ្ញាបនបត្របញ្ជាក់និមិត្តសញ្ញាគុណភាពផល ផលិតផលជលផលកម្ពុជា (CQS) ហើយប្រព័ន្ធនៃការផ្តល់វិញ្ញាបនបត្រនេះមានការលើកកម្ពស់សមភាពយេនឌ័រជាសូចនាករកំណត់មួយផងដែរ។

មន្ត្រីអធិការកិច្ចម្ហូបអាហារថ្នាក់ជាតិចំនួន ២៧ រូប (រួមមានស្ត្រី ១០ រូប) ដែលទទួលខុសត្រូវលើការផ្តល់វិញ្ញាបនប័ត្រ CQS នេះក៏ដូចជាអ្នកផ្តល់សេវាអភិវឌ្ឍន៍ធុរកិច្ចគាំទ្រដល់សហគ្រាស MSMEs បានទទួលការបណ្តុះបណ្តាលស្តីពីសមភាពយេនឌ័រ និងការពង្រឹងសិទ្ធិអំណាចដល់ស្ត្រីផងដែរ។

**ឯកឧត្តម ពុំ សុថា ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា ប្រធានរដ្ឋបាលជលផល (FiA)** បានមានប្រសាសន៍ថា «តាមរយៈការបញ្ជ្រាបយេនឌ័រនៅក្នុងគម្រោង រួមទាំងគោលនយោបាយស្តីពីយេនឌ័រ ការគាំទ្រអាជីវកម្ម ការគ្រប់គ្រងគម្រោង ការស្រាវជ្រាវនិងនវានុវត្តន៍ និងការកសាងសមត្ថភាពភាគីពាក់ព័ន្ធ គម្រោងបានបង្កើតផលជះរយៈពេលវែងលើការជំរុញសមភាពយេនឌ័រ និងពង្រឹងភាពអង់អាចដល់ស្ត្រីក្នុងវិស័យជលផលនៅកម្ពុជា។» ឯកឧត្តមបានសង្កត់ធ្ងន់ថាគម្រោង CAPFISH-Capture ដែលសហការអនុវត្តដោយ FiA និង UNIDO បានកសាងមូលដ្ឋានគ្រឹះដ៏រឹងមាំ ទ្រទ្រង់ដល់ផលជះជាវិជ្ជមាននៃសមភាពយេនឌ័រ និងភាពអង់អាចរបស់ស្ត្រីក្នុងវិស័យជលផលក្រោយប្រមូលផល ស្របតាមគោលនយោបាយលើកកម្ពស់សមភាពយេនឌ័រ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និង FiA ។

ផ្អែកលើគំនិតផ្តួចផ្តើមក្នុងការបង្កើនភាពប្រកួតប្រជែងរបស់វិស័យជលផលក្រោយប្រមូលផលរបស់កម្ពុជា គម្រោង មានកញ្ចប់ថវិកាគាំទ្រដល់គម្រោងស្រាវជ្រាវចំនួន ០៨ ដើម្បីដោះស្រាយបញ្ហាពាក់ព័ន្ធក្នុងវិស័យដោយគិតគូរអំពីតម្រូវការ និងឧបសគ្គរបស់ស្ត្រីក្នុងការពង្រីកប្រតិបត្តិការអាជីវកម្មរបស់ខ្លួន។ គួរកត់សម្គាល់ថា ក្នុងចំណោមគម្រោងស្រាវជ្រាវទាំងនេះ មាន ០៤ គម្រោងត្រូវបានដឹកនាំដោយអ្នកស្រាវជ្រាវជាស្ត្រី សហការជាមួយសាកលវិទ្យាល័យ និងវិស័យឯកជន។ បន្ថែមពីកិច្ចគាំទ្រខាងលើ គម្រោងបានគាំទ្រដល់ក្រុមស្ត្រីអ្នកកែច្នៃផលជលផលចំនួន ០៥ ដែលមានសមាជិកសរុបចំនួន ១៤១ នាក់ ដែលភាគច្រើនជាស្ត្រី។ សម្រាប់ជុំបន្ទាប់នៃកម្មវិធី VCIS គម្រោងនឹងជ្រើសរើសសហគ្រាស ២០ បន្ថែមទៀត ដោយកំណត់គោលដៅស្ត្រីជាម្ចាស់អាជីវកម្មយ៉ាងតិចបំផុត ៦០%។

«ការគាំទ្រដល់សហគ្រាសដឹកនាំដោយស្ត្រី គឺមានសារៈសំខាន់ណាស់សម្រាប់អភិវឌ្ឍសេដ្ឋកិច្ច និងនិរន្តរភាពនៃវិស័យជលផល។ ខណៈដែលអាជីវកម្មរបស់ពួកគេរីកចម្រើន វាមិនត្រឹមតែរួមចំណែកដល់សេដ្ឋកិច្ចយ៉ាងទូលំទូលាយប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដើរតួជាគំរូលើកទឹកចិត្ត និងជម្រុញស្ត្រីផ្សេងទៀតឱ្យក្លាយជាសហគ្រិន និងផ្លាស់ប្តូរវិសមភាពយេនឌ័រផងដែរ»។ នេះបើតាមការគូសបញ្ជាក់របស់លោក **Koen EVERAERT អនុប្រធានផ្នែកកិច្ចសហប្រតិបត្តិការរបស់គណៈប្រតិភូសហភាពអឺរ៉ុបប្រចាំនៅប្រទេសកម្ពុជា**។ លោកបានបន្ថែមថា «គំរូជោគជ័យរបស់គម្រោង CAPFISH-Capture អាចយកទៅអនុវត្តបាន ខណៈដែលឧត្តមានុវត្តន៍ទាំងនេះត្រូវបានចែករំលែកដើម្បីលើកកម្ពស់សហគ្រិនភាពជាស្ត្រី និងភាពអង់អាចផ្នែកសេដ្ឋកិច្ច»។

**សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង៖**


1- បណ្ឌិត ឈួន ចំណាន ប្រធាននាយកដ្ឋានបច្ចេកវិទ្យាកែច្នៃ និងគុណភាព (DFPTQ), FiA chhounchamnan@gmail.com
2- លោក អឹម សំរួល ជំនាញការប្រាស្រ័យទាក់ទងថ្នាក់ជាតិ គម្រោង CAPFISH-Capture, S.IM@unido.org
3- ផ្នែកសារព័ត៌មាននិងប្រាស្រ័យទាក់ទង ប្រតិភូសហភាពអឺរ៉ុបប្រចាំនៅកម្ពុជា: delegation-cambodia-ppi@eeas.europa.eu


សម្រាប់ព័ត៌មានគម្រោង:https://open.unido.org/projects/KH/projects/180039
ព្រឹត្តប័ត្រគម្រោង: http://newslettercapfish-postharvest.org/achieve